សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំ
ព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ
កំពង់ផែតាជេស និងកំពង់ផែកំពង់ហៅ ខេត្តកំពង់ឆ្នាំង
៣០ ឧសភា ២០១៣

**សូមគោរព ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសារធារណៈការ និងដឹកជញ្ជូន!**
**សូមគោរព ឯកឧត្តម សៀត គឹមលៀង អភិបាលរងខេត្តកំពង់ឆ្នាំង!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីសម្ពោធកំពង់ផែខ្នាតតូចពីរក្នុងឃុំតាជេស និងឃុំកំពង់ហៅក្នុងខេត្តកំពង់ឆ្នាំងជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន។ ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ ក្រសួងសាធារណៈការ និងដឹកជញ្ជូន អាជ្ញាធរ និងប្រជាពលរដ្ឋខេត្តកំពង់ឆ្នាំងដែលបានរៀបចំពិធីសម្ពោធនៅថ្ងៃនេះ។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលពិធីនេះត្រូវបានធ្វើឡើងក្នុងបរិបទនៃឆ្នាំ២០១៣នេះដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថាការអភិវឌ្ឍវិស័យដឹកជញ្ជូនមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីជួយជំរុញសកម្មភាពសេដ្ឋកិច្ច និងសង្គម។ ជាពិសេសសម្រាប់ប្រទេសកម្ពុជាដែលមានប្រភពធនធានទឹកដ៏សម្បូរបែបនេះ ការដឹកជញ្ជូនតាមដងស្ទឹងមានប្រសិទ្ធភាពខ្ពស់ និងមានតម្លៃថោក និងស្ទើរតែមិនអាចជំនួសបានសម្រាប់ប្រជាជនមូលដ្ឋាន។

ដោយទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យដឹកជញ្ជូនក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបាននិងកំពុងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាដែលមានដូចជាផ្លូវថ្នល់ កំពង់ផែ និងស្ពាន។ ខ្ញុំជឿជាក់ថាការកែលម្អកំពង់ផែក្នុងឃុំតាជេសនិងឃុំកំពង់ហៅនេះនឹងមិនត្រឹមតែជួយធ្វើឲ្យប្រសើរឡើងនូវសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់តែប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងជួយដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋងាយរងគ្រោះនៅតាមឃុំដែលនៅជុំវិញនេះផងដែរ។

ខ្ញុំបានដឹងថាកាលពីមុនកំពង់ផែក្នុងឃុំទាំងពីរធ្លាប់មានបញ្ហានិងមិនអាចដំណើរការប្រកបដោយប្រសិទ្ធភាពបានទេដែលធ្វើឲ្យប្រជាពលរដ្ឋមានការលំបាកក្នុងការធ្វើដំណើរឆ្លងកាត់ទន្លេសាប។ គម្រោងក្នុងឃុំទាំងពីរនេះមានគោលបំណងលើកស្ទួយសមត្ថភាពដឹកជញ្ជូនឆ្លងកាត់ទន្លេសាបតាមរយៈការកែលម្អកំពង់ផែ និងសាងសង់ផែបណ្តែតទឹក។ យើងរំពឹងថា គម្រោងទាំងពីរនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណប្រាំបីម៉ឺននាក់ដែលរស់នៅក្នុងឃុំចំនួន១៣។

ខ្ញុំសង្ឃឹមថាកំពង់ផែទាំងពីរនេះនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវដោយប្រជាជនក្នុងមូលដ្ឋាននេះ ដើម្បីទុកជានិមិត្តរូបនៃចំណងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជាកាន់តែយូរអង្វែងទៅមុខទៀត។

ចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងទាំងពីរនេះប្រព្រឹត្តិទៅដោយរលូន។ ខ្ញុំក៏សង្ឃឹមផងដែរថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុននិងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!